ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួន ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១- មុខងារនីតិកម្ម

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទីបួនស្តីពី វិសោធនកម្មកិច្ចព្រមព្រៀងវិនិយោគទូលំទូលាយអាស៊ាន

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់

- បានរៀបចំចាត់ចែងកិច្ចប្រជុំជាមួយតំណាងជនជាតិដើមភាគតិចចំនួន១៦អំបូរជនជាតិ ពាក់ព័ន្ធនឹងការស្នើសុំផ្តល់ជាតុចូលចំនួន៨ ចូលក្នុងសេចក្តីព្រាងវិសោធនកម្មច្បាប់ស្តីពី តំបន់ការពារធម្មជាតិឆ្នាំ២០០៨ និងច្បាប់ស្តីពី ព្រៃឈើឆ្នាំ២០០២ នៅវិមានព្រឹទ្ធសភា។

### ២- មុខងារតាមដានការអនុវត្តច្បាប់

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជួបពិភាក្សាការងារ និងផ្លាស់ប្តូរបទពិសោធន៍ការងារជូនគណៈកម្មការទី១ ព្រឹទ្ធសភា ជាមួយថ្នាក់ដឹកនាំលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប), តំណាងមកពី



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oumsarith_sgsenate@gmail.com, oumsarith_sgsenate@yahoo.com

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន នៅវិមានព្រឹទ្ធសភា

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំពិភាក្សាការងារជូនគណៈកម្មការទី៥ ព្រឹទ្ធសភា ជាមួយឯកឧត្តម **ខៀវ កាញារីទ្ធ** រដ្ឋមន្ត្រីក្រសួងព័ត៌មាន ដើម្បីឈ្វេងយល់អំពីលទ្ធផលការងារសម្រេចបានរបស់ក្រសួងព័ត៌មានក្នុងឆ្នាំ២០២១ និងទិសដៅអនុវត្តបន្តសម្រាប់ឆ្នាំ២០២២ ការគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន និងការកសាងសេចក្តីព្រាងច្បាប់ស្តីពី សិទ្ធិទទួលបានព័ត៌មាន នៅវិមានព្រឹទ្ធសភា

- បានរៀបចំកិច្ចប្រជុំដើម្បីត្រៀមជួបសវនាការជាមួយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងនឹងការជួញដូរ និងក្រសួងកិច្ចការនារី ព្រមទាំងគម្រោងរៀបចំអបអរសាទរទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ ឆ្នាំ២០២២ នៅវិមានព្រឹទ្ធសភា។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញ៖
  - ចូលរួមប្រារព្ធព្រះរាជពិធីថ្វាយព្រះរាជកុសលព្រះវិញ្ញាណក្ខន្ធ**ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ក្នុងព្រះរាជពិធីបុណ្យខួប១០០ព្រះវស្សា នៃការយាងប្រសូតថ្ងៃទី៣១ ខែតុលា ឆ្នាំ១៩២២ និងព្រះរាជពិធីបុណ្យគម្រប់ខួប១០ព្រះវស្សា នៃការយាងសោយព្រះទិវង្គតថ្ងៃទី១៥ ខែតុលា ឆ្នាំ២០១២ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** នៅព្រះបរមរាជវាំង
  - ទទួលព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** ស្តេចយាងនិវត្តន៍ពីទីក្រុងប៉េកាំងនៃសាធារណរដ្ឋប្រជាមានិតចិន
  - ចូលរួមពិធីលៀងសាយភោជន៍ផ្លូវរដ្ឋ ស្វាគមន៍ជូនចំពោះដំណើរទស្សនកិច្ចផ្លូវរដ្ឋរបស់ឯកឧត្តមបណ្ឌិត **ចូហ្សេ រ៉ាម៉ូស ហរតា** ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត និងគណៈប្រតិភូ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា** នៅព្រះបរមរាជវាំង

-បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និង **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញគោរពវិញ្ញាណក្ខន្ធសព ព្រឹទ្ធមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ **ទន់ ធី** ម្តាយក្មេក ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** ប្រធានក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ និងជាប្រធានគណៈកម្មាធិការជាតិ ជំរុញចលនាភូមិមួយផលិតផលមួយ នៅខេត្តត្បូងឃ្មុំ

-បានផ្តល់សេវា និងអមដំណើរ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា** ដង្ហែអង្គកឋិនទាន ទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស នៅវត្តចំនួន៩ ស្ថិតនៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

-បានផ្តល់សេវា និងអមដំណើរ **ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា ថ្វាយកម្រងផ្កា និងគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះវររាជបិតាជាតិខ្មែរ ព្រះបរមរតនកោដ្ឋ** នៅមណ្ឌបតម្កល់ព្រះបរមរូប រាជធានីភ្នំពេញ និងអញ្ជើញធ្វើបទឧទ្ទេសនាម ក្រោមប្រធានបទ "ភាពជាអ្នកដឹកនាំ" ជូនដល់សិក្ខាកាមដែលជាអភិបាលរងរាជធានី ខេត្តទាំង២៥ ដែលទើបទទួលបានការតែងតាំងថ្មី នៅទីស្តីការក្រសួងមហាផ្ទៃ

-បានរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមព្រះរាជពិធីគ្រងរាជសម្បត្តិរបស់**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**

-បានផ្តល់សេវាជូនប្រធានគណៈកម្មការទី២ព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងវគ្គបណ្តុះបណ្តាលស្តីពី ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៣ ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីមកពីខណ្ឌចំនួន០៧ រួមមាន៖ ខណ្ឌពោធិ៍សែនជ័យ ខណ្ឌដង្កោ ខណ្ឌមានជ័យ ខណ្ឌបឹងកេងកង ខណ្ឌទួលគោក ខណ្ឌជ្រោយចង្វារ ខណ្ឌព្រែកព្នៅ សរុបចំនួន ២៨៦នាក់ នៅរាជធានីភ្នំពេញ

-បានផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា និងយុវជនរាជសីហ៍ នាំយកកូនឈើប្រណិតចំនួន៧៨,៦២០ដើម ទៅដាំនៅរមណីយដ្ឋានភ្នំតាម៉ៅ ខេត្តតាកែវ

-បានផ្តល់សេវាជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមជាកិត្តិយសក្នុងវេទិកាជាតិអន្តរសាសនា ប្រឆាំងការជួញដូរមនុស្ស និងទេសភាពសម័យទំនើបលើកទី៦ ឆ្នាំ២០២២ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ និងចូលរួមជាកិត្តិយសក្នុងពិធីបើកអង្គសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២២ លើប្រធានបទ "ការស្តារឡើងវិញនៃប្រទេសកម្ពុជា៖ ការអភិវឌ្ឍប្រកបដោយនិរន្តរភាពបន្ទាប់ពីជំងឺកូវីដ-១៩" នៅរាជធានីភ្នំពេញ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ អាណត្តិទី៥ ឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ពិនិត្យហេដ្ឋារចនាសម្ព័ន្ធ សម្ពោធសមិទ្ធផលនានា ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋដែលរងគ្រោះដោយជំនន់ទឹកភ្លៀង និងបញ្ហាប្រឈមនានា ជាពិសេសបានអំពាវនាវឱ្យប្រជាពលរដ្ឋអញ្ជើញទៅពិនិត្យ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា នៅតាមមូលដ្ឋានរៀងៗខ្លួន ក្នុងភូមិភាគទាំង៨ ចំនួន១១លើក

- បានធ្វើបទបង្ហាញស្តីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់ព្រឹទ្ធសភា ជូនព្រះសង្ឃ សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច ខេត្តបាត់ដំបងចំនួន២៥នាក់

- បាននាំយកអំណោយរបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ចែកជូនកុមារកំព្រា នៅអង្គការបណ្តុះបណ្តាល និងថែរក្សាកុមារកំព្រា និងអង្គការកុមារកំព្រាភូមិថៃ ស្ថិតនៅឃុំត្រែងត្រយឹង ខេត្តកំពង់ស្ពឺ

- បានជួបសំណេះសំណាល និងនាំយកអំណោយរបស់សមាគមសប្បុរសធម៌ **បាវយ៉ាកង្វី** ទីក្រុងហូជីមិញ ចែកជូនប្រជាពលរដ្ឋជួបការលំបាកចំនួន២០០គ្រួសារ មកពីស្រុកកំពង់សៀម និងក្រុងកំពង់ចាម ខេត្តកំពង់ចាម ព្រមទាំងប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀងចំនួន១២៣គ្រួសារ នៅខេត្តព្រះវិហារ

- បានអញ្ជើញសួរសុខទុក្ខ និងចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពកុមារទាំង១១នាក់ ដែលបានបាត់បង់ជីវិតក្នុងឧបទ្ទវហេតុលិចទូក នៅខេត្តកណ្តាល

- បានផ្តល់សេវាជូនក្រុមការងាររបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តទៅពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ នៅខេត្តកណ្តាល

- បានរៀបចំពិធីសំណេះសំណាលជាមួយនិវត្តជន និងមន្ត្រីរាជការវ័យចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិ០១ តុលា

- បានរៀបចំសារលិខិតថ្វាយព្រះពរ និងជូនពរ របស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ទូលថ្វាយ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** និងឥស្សរជនជាន់ខ្ពស់តាមក្រសួង ស្ថាប័ននានា

-បានចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលទទួលបានភាពយុត្តិធម៌ និងភាពស្អាតស្អំ ពីតុលាការយុត្តិធម៌ទីក្រុងប៉ារីស សាធារណរដ្ឋបារាំង

- ញ្ញត្តិគាំទ្រចំពោះ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងការកម្ចាត់ចោលនូវមនោគមវិជ្ជាជ្រុលនិយមរបស់ពួជជនក្បត់ជាតិ៣ជំនាន់ ដែលជាមេក្រុមចលនាឧទ្ទាមក្រៅច្បាប់ និងបក្សពួក

-បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ និងគណៈប្រតិភូព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសពចំនួន០៥លើក ព្រមទាំងបានរៀបចំ និងផ្ញើសាររំលែកទុក្ខជូនគ្រួសារសពមន្ត្រីជាន់ខ្ពស់ចំនួន០៩លើក

-បានទទួលមន្ត្រីរាជការ សិស្ស និស្សិត និងសាធារណជនចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន១៨នាក់

-បានផលិត និងផ្សព្វផ្សាយទស្សនាវដ្តីប្រចាំខែតុលា ឆ្នាំ២០២២ ចំនួន៨០០ក្បាល

-បានទទួលពាក្យបណ្តឹងចំនួន០៤ករណី បញ្ជូនពាក្យបណ្តឹងទៅក្រសួង រាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន០៣ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី កំពុងពិនិត្យសិក្សាចំនួន០៧ករណី។

### ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងសវនាការជូន **សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋគុយបា និងប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យទីម័រខាងកើត

-បានរៀបចំចាត់ចែងជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ទៅបំពេញទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋសង្គមនិយមវៀតណាម

-បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំអន្តរជាតិ និងកម្មវិធីផ្សេងៗ រួមមាន៖ អញ្ជើញទស្សនកិច្ចការងារ នៅសភាសហព័ន្ធវ៉ាល់ឡូនី ព្រូចសែលព្រះរាជាណាចក្របែលហ្សិក និងទស្សនកិច្ចនៅសមាគមសណ្តែកសៀង និងចូលរួមកម្មវិធីពានរង្វាន់ស្បៀងអាហារពិភពលោក នៅសហរដ្ឋអាមេរិក, ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៥ (IPU-145) និងកិច្ចប្រជុំពាក់ព័ន្ធនានា នៅសាធារណរដ្ឋរ៉ាន់ដា, កិច្ចប្រជុំដើម្បីត្រៀមចូលរួមកិច្ចប្រជុំក្រុមការងារទទួលបន្ទុកការសើរើលក្ខន្តិកៈ(APF) និងមហាសន្និបាត

ប្រចាំឆ្នាំនៃបណ្តាញក្រុមសីលធម៌សមាជិកព្រឹទ្ធសភាប្រើភាសាបារាំង នៅសាធារណរដ្ឋបារាំង, កិច្ចប្រជុំប្រចាំឆ្នាំនៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក លើកទី៣០ (APPF-30th) នៅព្រះរាជាណាចក្រថៃឡង់ដ៍, កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងកម្មវិធីទស្សនកិច្ចផ្លូវការរបស់គណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅសាធារណរដ្ឋសង្គមនិយមវៀតណាម, កិច្ចប្រជុំនៃគណៈកម្មាធិការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ាលើកទី៤៣ (Committee on Organization Matters AIPA-43) ដើម្បីពិនិត្យអំពីវឌ្ឍនភាពការងាររបស់គណៈកម្មាធិការ និងបញ្ហាផ្សេងៗ នៅវិមានព្រឹទ្ធសភា, កិច្ចប្រជុំដើម្បីពិនិត្យខ្លឹមសារសេចក្តីសម្រេច និងឯកសារទស្សនាទាននៃគណៈកម្មាធិការរៀបចំមហាសន្និបាតអន្តរសភាអាស៊ានអាយប៉ាលើកទី៤៣ នៅវិមានរដ្ឋសភា, កិច្ចប្រជុំកំពូលអាស៊ានស្តីពី ស្ត្រីលើកទី២ ក្រោមប្រធានបទ "ការកសាងអនាគតប្រកបដោយចីរភាព បរិយាប័ន្ន និងកាន់តែរឹងមាំះ បំផុសសហគ្រិនស្ត្រីនៅអាស៊ាន" នៅវិមានសន្តិភាព

-បានផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញទទួលគណៈប្រតិភូសាធារណរដ្ឋកូរ៉េ មកបំពេញទស្សនកិច្ចសិក្សាឈ្វេងយល់អំពីកសិកម្ម កសិឧស្សាហកម្ម ដាំដុះចិញ្ចឹមកែច្នៃ និងហេដ្ឋារចនាសម្ព័ន្ធនានា នៅតំបន់អភិវឌ្ឍន៍កំពង់ផែឧកញ៉ា ម៉ុង កែវផុស

-ឯកឧត្តម **អ៊ុំ សារិទ្ធ** អគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យលោកស្រី **យូ បូរី** នាយកប្រតិបត្តិក្រុមហ៊ុនថៃឡឺន អ៊ិចសឹឡិន ឌីវេឡុបមិន ផាតនើរ ចូលជួបពិភាក្សាការងារ និងអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សាតំបន់(PCA) គណៈកម្មការប្រតិបត្តិ(PCA) និងកម្មវិធីបណ្តុះបណ្តាលកិច្ចការសភា នៅខេត្តសៀមរាប

-បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ស្ថានទូតសិង្ហបុរី, ស្ថានទូតម៉ាឡេស៊ី, ស្ថានទូតព្រុយណេ, ស្ថានទូតឥណ្ឌា, ស្ថានទូតថៃ, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី, អង្គការតម្លាភាពកម្ពុជា(TI Cambodia), អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម, ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា(CDC), មជ្ឈមណ្ឌលសភាអាស៊ី(PCA), វិទ្យាស្ថានSunrise, វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានGreatX Center, វិទ្យាស្ថានSalaCyber, វិទ្យាស្ថានMUT International College, វិទ្យាស្ថានProseth, ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, បណ្ណាល័យអាស៊ី-អឺរ៉ុប, ក្រុមហ៊ុន KOHA និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បានប្រជុំត្រួតពិនិត្យពិភាក្សាការងារសំខាន់ៗ និងលើកទិសដៅការងារសម្រាប់អនុវត្តបន្តរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំគណៈកម្មការជំរឿនមន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិ-ការដ្ឋានព្រឹទ្ធសភា។

### ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានរៀបចំរបាយការណ៍សមិទ្ធកម្មត្រីមាសទី៣ ឆ្នាំ២០២២ ដើម្បីពិនិត្យ និងកែសម្រួលក្នុងកម្រិតបច្ចេកទេស

- បានរៀបចំសមាសភាព(PFMRP) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ផ្ញើជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានបោះផ្សាយអាណត្តិឥណទានបន្ថែមសម្រាប់សម្តេចប្រធានព្រឹទ្ធសភា ទៅបំពេញបេសកកម្មនៅសាធារណរដ្ឋកូរ៉េ

- បានបើកប្រាក់បៀវត្សប្រចាំខែតុលា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានតាមដានគោលការណ៍ និងព័ត៌មានថ្មីទាក់ទងនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗ និងកំណត់បង្ហាញចំនួន០៤ច្បាប់

- បានធ្វើប័ណ្ណសម្គាល់ខ្លួន និងប័ណ្ណសមាជិក (ប.ស.ស) ចំនួន០៨ប័ណ្ណ

- បានស្រង់ស្ថិតិមន្ត្រីរាជការពិការភាព ដែលកំពុងបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០៦វគ្គ មានសិក្ខាកាមចូលរួមចំនួន១៤២នាក់ ព្រមទាំងសិក្ខាសាលា និងបាឋកថាក្នុងប្រទេសចំនួន០២លើក មានសិក្ខាកាមចូលរួមចំនួន៣២នាក់

- បានរៀបចំពិធីបាឋកថាស្តីពី ឈ្វេងយល់អំពីការបង្កើតសាធារណរដ្ឋប្រជាមានិតចិន និង

ការចែករំលែកគំរូភាពនៃភូមិមិត្តភាពចិន-កម្ពុជា

- បានធ្វើរបាយការណ៍វាយតម្លៃការធ្វើបទបង្ហាញរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៃវគ្គបណ្តុះបណ្តាលស្តីពី មូលដ្ឋានគ្រឹះនៃការប្រាស្រ័យឆ្លើយឆ្លងសភា (លើកទី៣) និងវគ្គការចែករំលែក និងបទពិសោធន៍លើការងារព័ត៌មាន និងការផ្សព្វផ្សាយនៅក្នុងបរិបទឌីជីថលចំនួន១៧អង្គភាព

- បានទទួលលិខិតចូលចំនួន២៨០ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៣២៩ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានាចំនួន០៨លើក

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានសង់ឃ្លាំង និងបន្ទប់ស្នាក់នៅរបស់អង្គភាពសន្តិសុខឡើងវិញនៅខាងក្រោយអគារE

- បានជួសជុលកែលម្អៈ ដំបូល សំយ៉ាបពិដានបន្ទប់រង់ចាំនៅស្ទាបខាងកើត-ខាងលិច សាលប្រជុំពេញអង្គ នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ អគារបណ្ណាល័យ និងបន្ទប់ទឹកសាលខាងត្បូង, ប្រព័ន្ធជណ្តើរយន្តនៅអគារសមាជិកព្រឹទ្ធសភា, ប្រព័ន្ធអគ្គិសនី, លាបថ្នាំអគារជប៉ុន និងអគារ F, កាំជណ្តើរអគារក្រហម, របងស័ង្កសីនៅក្រោយអគារA, និងប្តូរកម្រាលព្រំនៅបន្ទប់ទទួលភ្ញៀវសម្តេចប្រធានព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក, ត្រួតពិនិត្យសត្វកណ្តៀរ, ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម, បិទលេខកូដសម្ភារសារពើភណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន១២៥គ្រឿង/លើក

- បានបោកអ៊ុតកម្រាលតុ វាំងនន ជួសជុលតុប្រជុំ និងកៅអី នៅតាមសាលប្រជុំ និងអង្គភាពនានាចំនួន៩២ឈុត/គ្រឿង

- បានប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើងនៅតាមសាលប្រជុំ និងការប្រើប្រាស់ទឹក ភ្លើងក្រោយម៉ោងរដ្ឋបាល និងថ្ងៃឈប់សម្រាកចំនួន២៣លើក

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២២ ទូលថ្វាយ**ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជា-

ណាចក្រកម្ពុជា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែតុលា ឆ្នាំ២០២២ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាព ចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា។

**៥.២-ការងារសេវាច្បាប់៖**

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់ ពីរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន៣៨១ច្បាប់

- បានធ្វើកំណត់បង្ហាញរបាយការណ៍សវនកម្មចំនួន០៦ច្បាប់

- បន្តចងក្រងបញ្ជីអត្ថបទច្បាប់ ដែលព្រឹទ្ធសភាបានពិនិត្យ និងឱ្យយោបល់តាមឆ្នាំ និង នីតិកាលនីមួយៗ។

**៥.៣-ការងារស្រាវជ្រាវ៖**

- កំពុងសិក្សាស្រាវជ្រាវលើសេចក្តីព្រាងច្បាប់ចំនួន០១ច្បាប់

- បានតាមដាន និងចងក្រងក្របខណ្ឌគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម (ឆ្នាំ២០១៥-២០២៥)

- កំពុងសិក្សាស្រាវជ្រាវ ចងក្រង និងផលិតឯកសារលើប្រធានបទចំនួន១៤ប្រធានបទ

- បានផលិតនិងផ្សាយព្រឹត្តិបត្រស្រាវជ្រាវសេដ្ឋកិច្ច សង្គមស្តីពី បច្ចុប្បន្នភាពពាណិជ្ជកម្មសកល

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៩១អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែតុលា ឆ្នាំ២០២២ ចំនួន០៤ច្បាប់។

**៥.៤-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន០២លើក

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេក-វិទ្យាព័ត៌មានចំនួន៥២គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិក ព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភាចំនួន ១១៤ប្រធានបទ

-បានបន្តបំពាក់ឧបករណ៍អេឡិចត្រូនិចមានដូចជា កុំព្យូទ័រយួរដៃ កុំព្យូទ័រលើតុ និងIpad ជូនសមាជិកព្រឹទ្ធសភា និងអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៦គ្រឿង

-បានទទួលសៀវភៅច្បាប់ ឯកសារ និងសៀវភៅជំនាញផ្សេងៗចំនួន១៦០ក្បាល ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ អ៊ិតគ្របសៀវភៅ បញ្ជូនសៀវភៅទៅសេវាអ្នកអាន បិទប័ណ្ណខ្នង និងសងសៀវភៅចំនួន១៨១ក្បាល

-បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៥៨លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន២៧លើក

-បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុង Chanel Telegram ព័ត៌មានប្រចាំថ្ងៃចំនួន ២,០៧៤ប្រធានបទ

-បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា

-បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានលឿន ល្អ និងរលូន។

### ៥.៥-ការងារពិធីការ៖

-បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៩លើក

-បានកសាងជំនួយស្មារតី និងបកប្រែឯកសារនានា ជូនថ្នាក់ដឹកនាំព្រឹទ្ធសភាចំនួន១៣លើក

-បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៦ច្បាប់

-បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិ ប្រចាំខែតុលា ឆ្នាំ២០២២ ចំនួន០១ច្បាប់។

### ៥.៦-ការងារអគ្គាធិការដ្ឋាន៖

-បានប្រជុំពិភាក្សាការងារអំពីលទ្ធផលការងារសង្គមកិច្ច និងការផ្តល់សេវាជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២២ ចំនួន១៩លើក

-បានជួបប្រជុំពិភាក្សាការងារជាមួយអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងធ្វើរបាយការណ៍ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គ-

លេខាធិការដ្ឋានព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យជាក់ស្តែងតាមនាយកដ្ឋាន ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បញ្ជូនមកនាយកដ្ឋានគ្រប់គ្រងផ្ទៃក្នុងនៃអគ្គាធិការដ្ឋានរៀងរាល់ថ្ងៃ និងធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំ

- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃចំនួន២០លើក ប្រចាំសប្តាហ៍ចំនួន០៤លើក និងប្រចាំខែតុលា ឆ្នាំ២០២២

- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែតុលា ឆ្នាំ២០២២។

**II-លទ្ធផលការងារគាំទ្រលើមុខងារនាំមុខ៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៥០ច្បាប់

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៨ច្បាប់ ស្មើនឹង១៥៣នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន១១ច្បាប់ ស្មើនឹង១១នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២១០លីត្រ ជូនអង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៤៩២លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភាចំនួន១៤០សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៣៥លើក មានអ្នកចូលរួមចំនួន១,២២៤នាក់

- បានថតចម្លងឯកសារចំនួន៣,៨៩៣ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន៦៣ក្បាល អស់ក្រដាសចំនួន៥២,០៦១សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃ

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន២៧២លើក ស្មើនឹង៧២៥នាក់

-បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ និងចងបដា ពាក្យស្លោកចំនួន ១៥លើក

-បានផលិត និងផ្សព្វផ្សាយវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១៦លើក

-បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube និងFacebook ចំនួន៣៤១លើក

-បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់ កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន២៦លើក។

## II-**ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២២**

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ-១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ

+បន្តប្រឈមការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+លើកកម្ពស់សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេកវិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធ ការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា។

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គលើកទី៩ ព្រឹទ្ធសភា នីតិកាលទី៤ មានរបៀបវារៈដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣

២-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើ៖

៣.១-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មនៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ ដោយបន្ថែមមាត្រា៣សួន

៣.២-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥០(ក)នៃអនុសញ្ញាស្តីពី អាកាស-ចរណ៍ស៊ីវិលអន្តរជាតិ

៣.៣-ពិធីសារទាក់ទងនឹងការធ្វើវិសោធនកម្មមាត្រា៥៦ នៃអនុសញ្ញាស្តីពី អាកាសចរណ៍ស៊ីវិលអន្តរជាតិ។

### ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

- ត្រៀមរៀបចំពិធីជំនួបពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ជាមួយអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងការស្តារនីតិសម្បទាឡើងវិញ។

### ៣- មុខងារតំណាង

-ការឈានចូលវិស្សមកាលរបស់ព្រឹទ្ធសភា

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនៅមូលដ្ឋាន និងអាជ្ញាធរដែនដី ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា

-ត្រៀមបែបបទ ការបំពាក់គ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា សម្រាប់ចុងនីតិកាលទី៤

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំព្រឹទ្ធសភា អញ្ជើញចូលរួមពិធីបុណ្យឯករាជ្យជាតិ និងទិវាសិទ្ធិមនុស្សអន្តរជាតិ១០ធ្នូ

-ត្រៀមរៀបចំជូនសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២, ទី៤, ទី៥ និងទី៦ ចុះជួបសំណេះ-សំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ នៅខេត្តឧត្តរមានជ័យ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តព្រៃវែង ខេត្តស្វាយរៀង ខេត្តតាកែវ ខេត្តកំពត និងខេត្តកែប

-ត្រៀមរៀបចំជូនក្រុមសមាជិកាព្រឹទ្ធសភា ចុះជួបសំណេះសំណាលជាមួយក្រុមសមាជិកាឃុំ-សង្កាត់ នៅខេត្តសៀមរាប

-ត្រៀមរៀបចំវេទិកាជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៥ ទើបនឹងជាប់ឆ្នោតថ្មី នៃភូមិភាគទី៤ នៅខេត្តសៀមរាប (ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០២២)

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំក្នុងពិធីជំនួបជាមួយឥស្សរជនជាន់ខ្ពស់បរទេស និងអគ្គទូតនានានៃប្រទេសជាមិត្ត

-ត្រៀមចូលរួមកិច្ចប្រជុំ AIPA-ASEAN Interface (ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២) នៅព្រះរាជាណាចក្រកម្ពុជា, មហាសន្និបាតប្រចាំឆ្នាំនៃបណ្ដាញក្រុមសីលធម៌សមាជិកសភា និងកិច្ចប្រជុំការងារសើរើលក្ខន្តិកៈសភាប្រើភាសាបារាំង(APF) នៅសាធារណរដ្ឋបារាំង និងទស្សនកិច្ចការងារនៅសភាសហព័ន្ធវ៉ាលឡូនី-ព្រុចសែល ព្រះរាជាណាចក្របែលហ្ស៊ិក (ថ្ងៃទី០១-១៤ ខែវិច្ឆិកា ឆ្នាំ២០២២), មហាសន្និបាតសភាប្រើភាសាបារាំង(APF) តំបន់អាស៊ី-ប៉ាស៊ីហ្វិក លើកទី១០ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម (ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២២), មហាសន្និបាត(AIPA), (APF), (IPU) និងកិច្ចប្រជុំពាក់ព័ន្ធ

-ត្រៀមរៀបចំមហាសន្និបាតអាយប៉ាលើកទី៤៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ

-ផ្ដល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាតសិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្ដុះបណ្ដាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃបរិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា(MOU) ជាមួយឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស មជ្ឈមណ្ឌលសភាអាស៊ី(PCA)

និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី

-ជំរុញកម្មវិធីបណ្តុះបណ្តាលមន្ត្រីក្នុង និងក្រៅប្រទេស តាមកម្មវិធីសហប្រតិបត្តិការជាមួយភាគីជាមិត្ត និងដៃគូផ្សេងៗទៀត

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិចសកម្មភាពច្រើន

-ត្រៀមរៀបចំសិក្ខាសាលាស្តីពី សហគមន៍ជោគវាសនារួមកម្ពុជា-ចិន ប្រកៀកស្មាគ្នាឆ្ពោះទៅមុខក្នុងដំណើរថ្មី

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំកម្មវិធីធ្វើអត្តសញ្ញាណប័ណ្ណជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ផុតសុពលភាពក្នុងដើមឆ្នាំ២០២៣)

-ការបញ្ចប់ផែនការការងារដំណាច់ឆ្នាំ បូកសរុប និងលើកទិសដៅឆ្នាំថ្មី

-ត្រៀមរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ និងការបែងចែកឥណទានឆ្នាំ២០២៣ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

-បន្តតាមដានជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតនៃសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំព្រះរាជាណាចក្រកម្ពុជា គម្រោងស្នើកសាងអគារថ្មី១ខ្នង និងការស្វែងរកជំនួយពីរដ្ឋាភិបាលនៃប្រទេសជាមិត្តសម្រាប់នីតិកាលថ្មីខាងមុខ និងការស្នើសុំឥណទានបន្ថែមពីរាជរដ្ឋាភិបាល

-ត្រៀមប្រជុំគណៈកម្មការទ្រទ្រង់មូលនិធិគន្ធបុប្ផាកម្ពុជា ប្រចាំព្រឹទ្ធសភា

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២២ និងប្រាក់ឧបត្ថម្ភផ្សេងៗ ឱ្យបានទាន់ពេលវេលា

-ត្រៀមរៀបចំបែបបទដំឡើងប្រាក់បំណាច់មុខងារដល់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាសម្រាប់ឆ្នាំ២០២៣ និងត្រៀមឧបត្ថម្ភបន្ថែមប្រាក់សោធននិវត្តន៍ដល់អតីតនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-បន្តវិចារណកម្មថវិកា៖ សន្សំសំចៃ និងអាទិភាពចំពោះតែការងារចាំបាច់បន្ទាន់ និងប្រញាប់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-ត្រៀមរៀបចំឯកសារគោលស្តីពី តួនាទី ភារកិច្ច របស់នាយកដ្ឋាន និងអង្គភាពចំណុះអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារពិពណ៌នាការងារ និងបញ្ជាក់ពីសមត្ថភាពធ្វើការងាររបស់មន្ត្រីរាជការ

-ត្រៀមរៀបចំគោលការណ៍ គោលនយោបាយថ្មី ស្របតាមដំណើរការងារ និងស្ថានភាពជាក់ស្តែងចំនួន០៣គឺ៖

១-គោលការណ៍ស្តីពី ការផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការមានស្នាដៃឆ្នើម
២-គោលការណ៍ស្តីពី ការវាយតម្លៃការបំពេញការងាររបស់មន្ត្រីរាជការ
៣-គោលនយោបាយស្តីពី ការគ្រប់គ្រងធនធានមនុស្ស

-ត្រៀមធ្វើជំរឿនសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ តម្រូវការ និងការប្រឈម

-ត្រៀមធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា លើកកម្ពស់សមត្ថភាពដឹកនាំ និងគ្រប់គ្រងគ្រប់កម្រិត គ្រប់វិស័យ ពង្រឹងពង្រីកសមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនងសាធារណៈ

-ធ្វើបច្ចុប្បន្នភាពផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល១០ឆ្នាំ (២០២២-២០៣០) របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ធ្វើសម្រង់តម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់មន្ត្រីរាជការប្រចាំឆ្នាំ២០២៣

-កសាងផែនការបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២៣

-ត្រៀមឧទ្ទេសនាមជូនកម្មសិក្សាការីសាលាភូមិន្ទរដ្ឋបាល

-ត្រៀមបើកវគ្គបណ្តុះបណ្តាលលើមុខជំនាញដែលជាតម្រូវការចាំបាច់របស់ស្ថាប័ន

-ត្រៀមបណ្តុះបណ្តាលគ្រូបង្គោលសូចនាករ សមិទ្ធកម្មគន្លឹះ(KPI) តាមអគ្គនាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ត្រៀមបញ្ជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវគ្គបណ្តុះបណ្តាល កិច្ចការសភា នៅសាលារដ្ឋបាលជាតិបារាំង និងនៅប្រទេសកាណាដា

-ធ្វើបច្ចុប្បន្នភាពជំរឿនស្ថិតិសមត្ថភាពជំនាញរបស់មន្ត្រីរាជការប្រចាំឆ្នាំ និងធ្វើជំរឿនមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ឆ្នាំ២០២២

-សិក្សាគម្រោង និងប្លង់សាងសង់សាលប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ថ្មី និងប្លង់សាងសង់ របងថ្មីខាងមុខព្រឹទ្ធសភា

-បន្តការងារជួសជុលថែទាំអគារ ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា អគារបណ្ណាល័យ គូសគំនូសចរាចរ ចំណតយានយន្ត និងជួសជុលផ្លាស់ប្តូរគ្រឿងបរិក្ខារផ្សេងៗនៅតាមអគារ

-ការរៀបចំជួសជុលកែលម្អសាលសវនាការ នៅអគារក្រហម

-កែលម្អបរិស្ថាន និងអនុវត្តការងារជួសជុលផ្សេងៗក្នុងករណីចាំបាច់ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងវិន័យការងារ

-ត្រៀមរៀបចំផែនការការងារសម្រាប់ការត្រៀមទទួលនីតិកាលទី៥របស់ព្រឹទ្ធសភា និងការ ត្រៀមជាបណ្តើរៗ ការរៀបចំជួសជុលកែលម្អភោជនាគារចនាសម្ព័ន្ធ អគារការិយាល័យធ្វើការ រួមទាំង បំពាក់សម្ភារៈ

-ត្រៀមធ្វើរបាយការណ៍បូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឆ្នាំ២០២២ និងទិសដៅការងារឆ្នាំ២០២៣

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារ អេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ព្រមទាំងការចូលរួមវគ្គផ្សេងៗ រៀបចំដោយសភា នៃប្រទេសជាមិត្ត (ឥណ្ឌា...)

-ត្រៀមរៀបចំផលិតវីដេអូព័ត៌មានរបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-ការបោះពុម្ពទិនានុប្បវត្តិ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវធានាគុណភាព និងបរិមាណ សមស្របតាមកម្មវិធីបុណ្យជាតិ បុណ្យប្រពៃណី និងកម្មវិធីផ្សេងៗទៀតត្រូវធានាការអនុវត្តឱ្យបានទាន់ពេលវេលា។

IV-**សេចក្ដីសន្និដ្ឋាន**

ក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញភារកិច្ច និងផ្ដល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងារស្នូលទាំង៣ បានល្អគាប់ប្រសើរ ដោយបានរៀបចំចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០២លើក និងប្រជុំពេញអង្គចំនួន០១លើក និងបានជួបសវនាការការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងការចុះបំពេញមុខងារតំណាង តាមបណ្ដាខេត្ត ក្រុងនានាបានល្អ និងទាន់ពេលវេលា។

ចំពោះការងារសហប្រតិបត្តិការអន្តរជាតិ បានរៀបចំបែបបទ ផ្ដល់សេវា និងអមដំណើរ ***សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា*** អញ្ជើញបំពេញទស្សនកិច្ចផ្លូវការ នៅសាធារណរដ្ឋសង្គមនិយមវៀតណាម និងជំនួបសវនាការជាមួយថ្នាក់ដឹកនាំប្រទេសជាមិត្តចំនួន០២លើក ព្រមទាំងកិច្ចប្រជុំអន្តរជាតិនានា បានយ៉ាងរលូន។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការនានា ដែលរាជរដ្ឋាភិបាល និងក្រសួងសុខាភិបាលបានដាក់ចេញ ជាពិសេសវិធានការ "៣ការពារ ៣កុំ" និងការចាក់វ៉ាក់សាំងដូសជំរុញឱ្យបានគ្រប់ៗគ្នាកុំបីខាន ដើម្បីការពារមិនឱ្យជំងឺកូវីដ-១៩ អាចឆ្លងរាលដាលជាថ្មីទៀតបាន។

ថ្ងៃព្រហស្បតិ៍ ២រោច ខែកត្ដិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ, ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២២

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ